៤-ព្រះរាជក្រឹត្យ នស/រកត/០១៩៩/១៨

# ព្រះរាជក្រឹត្យ

នស/រកត/០១៩៩/១៨

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដា ឆ្នាំ១៩៩៤ ស្តីអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០៧/នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប – អង្គរ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១១ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរ " អប្សរា "
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់សេចក្តីសំរេចរបស់គណៈកម្មាធិការបេតិកភ័ណ្ឌពិភពលោកក្នុងសម័យប្រជុំសាមញ្ញចាប់ពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២ នៅសាន់តាហ្វេ ន្យូម៉ិកស៊ិក សហរដ្ឋអាមេរិក និងសម័យប្រជុំលើកទី១៩ នៅប៊ែរឡាំងប្រទេសអាល្លឺម៉ង់ ចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៩៥ ដែលចាត់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ចូលក្នុងបញ្ជីនៃបេតិកភ័ណ្ឌពិភពលោកត្រូវអន្តរាយ
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៩៩

## ប្រកាសបង្គាប់

មាត្រា១ : កែសំរួលបទបញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខនស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ "អប្សរា" ឱ្យស្របជាមួយបទបញ្ញត្តិនៃព្រះរាជក្រឹត្យលេខនស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ។

មាត្រា២ : –រាជរដ្ឋាភិបាលមានកាតព្វកិច្ចគោរព និងការពាររមណីយដ្ឋានអង្គរដែលជាបេតិកភ័ណ្ឌពិភពលោក សំដៅធានាគ្រប់គ្រង និងរក្សានូវនិរន្តរភាពនៃលក្ខណៈសម្បត្តិរបស់រមណីយដ្ឋានអង្គរ។

–រាល់វិធានការ និងការអនុញ្ញាតទាំងឡាយណាដែលចេញដោយអាជ្ញាធរជាតិ ឬ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ដែលមានវិសមិតភាព ជាមួយកាតព្វកិច្ចអន្តរជាតិ ដែលតម្រូវឱ្យប្រទេសកម្ពុជាគោរព និងអនុវត្ត ត្រូវទុកជានិរាករណ៍ ។

មាត្រា៣ : ផ្នែកបច្ចេកទេសនៃអាជ្ញាធរអប្សរា និងបណ្តាអង្គភាពទទួលខុសត្រូវការគ្រប់គ្រងតំបន់រមណីយដ្ឋានអង្គរ ត្រូវដាក់ឱ្យស្ថិតនៅក្រោមអាណាព្យាបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី ស្របតាមបទបញ្ញត្តិចែងក្នុងមាត្រា២៩, ៣០, ៣១, ៣២ និង៣៣ នៃព្រះរាជក្រឹត្យលេខនស/រកត/១២៩៧/៩១ ។

អាណាព្យាបាលហិរញ្ញវត្ថុ និងគណនីអាជ្ញាធរអប្សរាត្រូវស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមបទបញ្ញត្តិចែងក្នុងមាត្រា ៣៤, ៣៥ , ៣៦ និង៣៧ នៃព្រះរាជក្រឹត្យលេខនស/រកត/១២៩៧/៩១ ។

មាត្រា៤ : សមាសភាពក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរអប្សរាមានដូចតទៅ :

| | |
|---|---|
| – ទីប្រឹក្សារាជរដ្ឋាភិបាលផ្នែកការងារអប្សរា | |
| – តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១នាក់ |
| – តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១នាក់ |
| – តំណាងក្រសួងមហាផ្ទៃ | ១នាក់ |
| – តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១នាក់ |
| – តំណាងក្រសួងទេសចរណ៍ | ១នាក់ |
| – តំណាងក្រសួងបរិស្ថាន | ១នាក់ |
| – តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | ១នាក់ |
| – តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | ១នាក់ |
| – អភិបាលខេត្តសៀមរាប | ១នាក់ |
| –តំណាងបុគ្គលិកអាជ្ញាធរអប្សរា | ១នាក់ |

សមាជិកក្រុមប្រឹក្សាភិបាលត្រូវតែងតាំងឡើងដោយអនុក្រឹត្យ ហើយអាចរំសាយដោយអនុក្រឹត្យនៅពេលណាក៏បាន ។

អាណត្តិសមាជិកក្រុមប្រឹក្សាភិបាល មានរយៈពេល៣ឆ្នាំ ហើយអាចបន្តសាជាថ្មីបាន។ ការបញ្ចប់អាណត្តិរបស់សមាជិកណាម្នាក់ ត្រូវធ្វើឡើងតាមសំណើនៃក្រសួងដែលសមាជិកនោះ តំណាងឱ្យ ។

រដ្ឋទទួលខុសត្រូវបទស៊ីវិល ដែលពាក់ព័ន្ធទៅនឹងការបំពេញបេសកកម្មរបស់សមាជិកក្រុមប្រឹក្សាភិបាល លើកលែងតែក្នុងករណីធ្វើខុសដោយចេតនា ។ សមាជិកក្រុមប្រឹក្សាភិបាលទទួលខុសត្រូវផ្ទាល់លើកំហុសព្រហ្មទណ្ឌដែលខ្លួនបានប្រព្រឹត្ត ។

មាត្រា៥ : អាជ្ញាធរអប្សរាត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធានក្រុមប្រឹក្សាភិបាលដែលមានតួនាទី និងមុខតំណែងជាប្រធានអគ្គនាយក ស្របតាមមាត្រា១១.១ នៃព្រះរាជក្រឹត្យ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ និងអគ្គនាយករងមួយចំនួនទៀតជាជំនួយការ ។

បន្ថែមលើសិទ្ធិអំណាចចែងក្នុងមាត្រា១២ នៃព្រះរាជក្រឹត្យ នស/រកត/១២៩៧/៩១ ប្រធានអគ្គនាយកមានតួនាទីភារកិច្ចដូចតទៅ :

–តំណាងរាជរដ្ឋាភិបាល ក្នុងគ្រប់កិច្ចប្រជុំ គ្រប់ពិធី និងគ្រប់ការចរចាដែលពាក់ព័ន្ធនឹងតំបន់រមណីយដ្ឋានអង្គរ ។

–មានសិទ្ធិចុះហត្ថលេខាលើកិច្ចព្រមព្រៀង លើពិធីសារ លើកិច្ចសន្យាទាំងឡាយដែលទាក់ទងនឹងតំបន់រមណីយដ្ឋានអង្គរ ក្រោយពីទទួលបានការឯកភាពពីរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលផ្នែកបច្ចេកទេស ។

–ជាអាណាប័កដើមខ្សែនៃអាជ្ញាធរអប្សរា និងជាអ្នកពិនិត្យចំណូលប្រាក់ ទូទាត់ចំណូលពាក់ព័ន្ធធ្វើការទូទាត់ និងចេញបញ្ជាចំណាយ ។

–អាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិ ឬបង្កើតឱ្យមានការព្រមព្រៀងជាគណនេយ្យករនូវរជ្ជទេយ្យ ចំណូល ឬបុរេប្រទាន ។

–ប្រធានអគ្គនាយកត្រូវបានតែងតាំង ឬបញ្ឈប់ពីតំណែងដោយព្រះរាជក្រឹត្យ ។

–មាត្រា៨ និង៩ នៃព្រះរាជក្រឹត្យនស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ត្រូវទុកជានិរាករណ៍ ។

មាត្រា៦ :

១–អាជ្ញាធរអប្សរាទទួលបន្ទុកការពារ អភិរក្ស និងទ្រទ្រង់តំបន់រមណីយដ្ឋានអង្គរ ស្របតាមបទបញ្ញត្តិចែងក្នុងមាត្រា៥ នៃព្រះរាជក្រម នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការបេតិកភ័ណ្ឌវប្បធម៌ ព្រមទាំងកាតព្វកិច្ចអន្តរជាតិដែលតម្រូវឱ្យតំបន់រមណីយដ្ឋានអង្គរ រក្សានូវលក្ខណៈសម្បត្តិជាបេតិកភ័ណ្ឌពិភពលោក ។

ដើម្បីបំពេញបេសកកម្មនេះ អាជ្ញាធរអប្សរាមានសិទ្ធិផ្តាច់មុខ ក្នុងការចេញលិខិតអនុញ្ញាតសាងសង់សំរាប់ការស្ថាបនាទាំងឡាយក្នុងវង្វង់តំបន់រមណីយដ្ឋានអង្គរ ។ ការអនុញ្ញាតសាងសង់

ដែលចេញដោយអាជ្ញាធរផ្សេងពីអប្សរា ទាក់ទងនឹងសំណង់នៅក្នុងតំបន់រមណីយដ្ឋាន ត្រូវទុកជាមោឃៈ ។

សំណង់កសាងរួចហើយដែលគ្មានច្បាប់អនុញ្ញាត អាចត្រូវរុះរើចេញ ដោយម្ចាស់សំណង់ល្មើសច្បាប់ ហើយគ្មានលើកខ័ណ្ឌក្នុងរយៈពេល៤៥ថ្ងៃយ៉ាងយូរ គិតពីថ្ងៃជូនដំណឹង ។

២–តំបន់២ ដែលជា "ឧទ្យានបុរាណវត្ថុត្រូវការពារ" ហើយដែលមានចែងក្នុងមាត្រា៤ នៃព្រះរាជក្រឹត្យ ០១/នសចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ត្រូវចាត់ទុកជាអចលនទ្រព្យសម្បត្តិរបស់រដ្ឋ ។ រាល់ការលក់ដូរ ដោះដូរ ឬសម្បទានអ្វីមួយ នៅលើដីធ្លី ដែលស្ថិតក្នុងតំបន់២ ត្រូវចាត់ទុកជាមោឃៈ ។

៣–ដោយហេតុថាតំបន់រមណីយដ្ឋានអង្គរជាបេតិកភ័ណ្ឌពិភពលោក អាជ្ញាធរអប្សរាត្រូវទទួលភារកិច្ចផ្តាច់មុខជាអ្នកចាត់ចែងពិធីគ្រប់ជំពូកទាំងអស់ ក្នុងបរិវេណរមណីយដ្ឋានអង្គរ ។

មាត្រា៧ : ក្រៅពីធនធានដែលមានចែងក្នុងមាត្រា១៩ នៃព្រះរាជក្រឹត្យនស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ប្រាក់ចំណូលរបស់អាជ្ញាធរអប្សរាបានមកពីប្រភពដូចខាងក្រោមនេះ :

–ការចូលទស្សនាប្រាសាទស្ថិតនៅក្នុងបរិវេណតំបន់១ ដូចមានចែងក្នុងមាត្រា៣ នៃព្រះរាជក្រឹត្យ លេខ០១/នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៥ ។

–កំរៃយកពីអាជីវកម្មថតរូប ឬថតខ្សែភាពយន្តក្នុងបរិវេណតំបន់នោះ ។

–ពិធីសិល្បៈ – ពិធីវប្បធម៌ និងពិធីផ្សេងៗទៀត ដែលចាត់ចែងដោយអាជ្ញាធរអប្សរា ឬដោយភាគីឯកជនដែលបានទទួលការអនុញ្ញាតពីអាជ្ញាធរអប្សរា ។

–សម្បទាន ការជួល ឬការអនុញ្ញាតឱ្យប្រើដីធ្លីដែលគ្រប់គ្រងដោយអាជ្ញាធរអប្សរា ។

–ការឧបត្ថម្ភស្របតាមច្បាប់ ។

មាត្រា៨ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៩ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចព្រះរាជក្រឹត្យនេះ ។

មាត្រា១០ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

ថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៩

លេខ : [illegible] ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ១៩៩៩

អគ្គលេខាធិការរាជរដ្ឋាភិបាល